ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
លេខ ៧១៥ អពដ

GENERAL DEPARTMENT OF TAXATION

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៤

# សេចក្តីជូនដំណឹង
## ស្តីពីបែបបទនៃការដាក់ពាក្យស្នើសុំ ឈប់ប្រកបអាជីវកម្មជាស្ថាពរ និងជម្រះបញ្ជីសារពើពន្ធ

អគ្គនាយកដ្ឋានពន្ធដារមានកិត្តិយសជម្រាបជូន លោក-លោកស្រី ជាអភិបាល បណ្ណាធិការ ឬកម្មសិទ្ធិករសហគ្រាស ដែលជាអ្នកជាប់ពន្ធធំទាំងអស់ និងអ្នកជាប់ពន្ធមធ្យមដែលមានអាសយដ្ឋានក្នុងរាជធានីភ្នំពេញ មេត្តាជ្រាបថា ដើម្បីពង្រឹងការគ្រប់គ្រងរដ្ឋបាលសារពើពន្ធ និងពន្លឿនដំណើរការសវនកម្មសារពើពន្ធលើសហគ្រាសស្នើសុំឈប់ប្រកបអាជីវកម្មជាស្ថាពរ និងស្នើសុំជម្រះបញ្ជីសារពើពន្ធ សហគ្រាសត្រូវអនុវត្តតាមបែបបទដូចខាងក្រោម៖

**១- ចំពោះសហគ្រាសស្នើសុំឈប់ប្រកបអាជីវកម្មជាស្ថាពរ÷**

ក- សហគ្រាសត្រូវបំពេញគ្រប់ព័ត៌មាន តាមការតម្រូវក្នុងទម្រង់ពាក្យស្នើសុំដែលចេញដោយរដ្ឋបាលសារពើពន្ធ និងភ្ជាប់មកជាមួយនូវលិខិតស្នើសុំឈប់ប្រកបអាជីវកម្មរបស់អ្នកជាប់ពន្ធ ច្បាប់ដើមនៃបណ្ណ័ប៉ាតង់ឆ្នាំចុងក្រោយ ច្បាប់ដើមនៃវិញ្ញាបនបត្រអាករលើតម្លៃបន្ថែម លក្ខន្តិកៈក្រុមហ៊ុន និង/ឬ វិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីពាណិជ្ជកម្ម លិខិតប្រកាសពន្ធប្រចាំខែចំនួនបីខែចុងក្រោយ និងលិខិតប្រកាសប្រចាំឆ្នាំ សម្រាប់ឆ្នាំជាប់ពន្ធចុងក្រោយ និងឆ្នាំជាប់ពន្ធដែលស្នើសុំឈប់ ព្រមទាំងលិខិតជូនដំណឹងស្តីពីការកំណត់ពន្ធឡើងវិញគ្រប់ការិយបរិច្ឆេទ។

ខ- សហគ្រាសត្រូវបង់ពន្ធប្រថាប់ត្រាចំនួន ១លានរៀល ក្នុងការសុំឈប់អាជីវកម្មជាស្ថាពរតាមបទប្បញ្ញត្តិស្តីពីពន្ធប្រថាប់ត្រា ចូលក្នុងគណនីអង្គភាពពន្ធដារដែលគ្រប់គ្រងសហគ្រាសផ្ទាល់ និងភ្ជាប់លិខិតបញ្ជាក់ការបង់ពន្ធនេះមកជាមួយនៅពេលដាក់លិខិតស្នើសុំ។

**២- ចំពោះសហគ្រាសស្នើសុំជម្រះបញ្ជីសារពើពន្ធ÷**

សហគ្រាសត្រូវដាក់លិខិតស្នើសុំដែលមានបញ្ជាក់នូវការិយបរិច្ឆេទស្នើសុំជម្រះបញ្ជីសារពើពន្ធ និងភ្ជាប់មកជាមួយនូវលិខិតជូនដំណឹងស្តីពីការកំណត់ពន្ធឡើងវិញគ្រប់ការិយបរិច្ឆេទ។

ចំពោះការស្នើសុំទាំងពីរប្រភេទខាងលើ សហគ្រាសត្រូវដាក់ពាក្យស្នើសុំមកអគ្គនាយកដ្ឋានពន្ធដារ ដោយបញ្ជាក់ឱ្យបានច្បាស់លាស់នូវ ឈ្មោះសហគ្រាសជាអក្សរខ្មែរនិងឡាតាំង លេខអត្តសញ្ញាណកម្មសារពើពន្ធ អាសយដ្ឋានបច្ចុប្បន្នរបស់សហគ្រាស លេខទូរស័ព្ទដែលអាចទាក់ទងនឹងសហគ្រាសបាន និងភ្ជាប់មកជាមួយនូវច្បាប់ចម្លងនៃអត្តសញ្ញាណបណ្ណ ឬលិខិតឆ្លងដែនរបស់អភិបាល បណ្ណាធិការ ឬកម្មសិទ្ធិករសហគ្រាស។

ពាក្យស្នើសុំត្រូវចុះហត្ថលេខាដោយ អភិបាល បណ្ណាធិការ ឬកម្មសិទ្ធិករសហគ្រាស ឬអ្នកតំណាងដែលមានលិខិតផ្ទេរសិទ្ធិស្របច្បាប់។

អគ្គនាយកដ្ឋានពន្ធដារសង្ឃឹមជឿជាក់ថា លោក-លោកស្រីជា អភិបាល បណ្ណាធិការ ឬកម្មសិទ្ធិករសហគ្រាស ពិតជាយកចិត្តទុកដាក់អនុវត្តតាមខ្លឹមសារនៃសេចក្តីជូនដំណឹងនេះឱ្យមានប្រសិទ្ធភាព។

ប្រតិភូរាជរដ្ឋាភិបាល
ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ

គង់ វិបុល

Collection by VCAT Professional Consultant

អាគារកែងមហាវិថី សហព័ន្ធរុស្ស៊ី(១១០)និង ម៉ៅសេទុង(២៥៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ (+855) 23 886 708 ទូរសារ: (+855)23 886 700, Email: gdt@tax.gov.kh, Website: www.tax.gov.kh